# I .ទីស្តីការគណៈរដ្ឋមន្ត្រី

## ១-អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៥

### អនុក្រឹត្យលេខ ៤១ អនក្រ.បក

ស្តីពីការបញ្ជាចំណាយឥតគ្រោងទុក ដែលមានលក្ខណៈ
ចាំបាច់ និង បន្ទាន់ របស់ក្រសួងការពារជាតិ

* * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### សំរេច

**មាត្រា ១ :** កំណត់អោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោះស្រាយថវិកាសំរាប់ការចំណាយក្រៅគំរោងផែនការ ដែលចាត់ទុកជាការប្រញាប់របស់ក្រសួងការពារជាតិ តាមអាទិភាព ដែលមានជាលំដាប់លំដោយដូចខាងក្រោម ÷

១-ការចំណាយមានចំនួនទឹកប្រាក់ : ៨.៤៤៤.០០០.០០០៛០០ (ស្មើនឹង ៣.៣៧៧.៦០០$) សំរាប់បំពេញកង្វះការចំណាយឆ្នាំ ១៩៩៤ របស់អគ្គសេនាធិការ ។

២-ការចំណាយមានចំនួនទឹកប្រាក់ : ៧៩២.០០០$ ដុល្លារអាមេរិក សំរាប់ទូទាត់ថ្លៃទំនិញពិសេស គ្រាប់បួម ។

www.pheakdeylaw.com

៣-ការចំណាយមានចំនួនទឹកប្រាក់ : ៦១៩.៨០០$ ដុល្លារអាមេរិក សំរាប់ជួសជុលអគ្គបញ្ជាការដ្ឋាន ។

៤-ការចំណាយមានចំនួនទឹកប្រាក់ : ១.៥៩៩.៥០០$ ដុល្លារអាមេរិក សំរាប់ទូទាត់ជំហានទី ១ ថ្លៃទិញយន្តហោះ L39 ចំនួន ៧ គ្រឿង និង ជួសជុលយន្តហោះ MIG 21 ចំនួន ៨ គ្រឿង ។

៥-ការចំណាយមានចំនួនទឹកប្រាក់ : ៤២៤.៦៣៣,៥០$ ដុល្លារអាមេរិក សំរាប់ទូទាត់ជំហានទី ២ និង ទី ៣ ថ្លៃទិញយន្តហោះ Y-12 ចំនួន ២ គ្រឿង ។

៦-ការចំណាយមានចំនួនទឹកប្រាក់ : ១.៤៦០.០០០$ ដុល្លារអាមេរិក សំរាប់ទិញគ្រឿងឧបករណ៍ពេទ្យបំពាក់អោយអាគារបំរើអោយការវះកាត់ នៅមន្ទីរពេទ្យព្រះកេតុមាលា ។

៧-ការចំណាយមានចំនួនទឹកប្រាក់ : ៦៧.៧៨៥$ ដុល្លារអាមេរិក សំរាប់ទិញសំភារៈប្រើប្រាស់ នៅអគ្គប. ្ជាការដ្ឋាន ។

៨-ការចំណាយទឹកប្រាក់ចំនួន : ១.០០០.០០០$ ដុល្លារអាមេរិក សំរាប់សងលោកឧញ៉ា ថេង ប៊ុនម៉ា ។

សរុបទឹកប្រាក់ទាំងអស់ចំនួន : ៩.៣៤១.៣១៨,៥០$ ដុល្លារអាមេរិក (ប្រាំបួនលានបីរយសែសិបមួយពាន់ បីរយដប់ប្រាំបីដុល្លារអាមេរិក និង ហាសិបសេន) ។

**មាត្រា ២:** ចំពោះថវិកាចំណាយរបស់ក្រសួងការពារជាតិ ក្រៅពីការកំណត់ក្នុងមាត្រាខាងលើ រាជរដ្ឋាភិបាលនឹងកំណត់អោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោះស្រាយជាក្រោយ។

**មាត្រា ៣:** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលការអនុវត្តន៍តាមអនុក្រឹត្យនេះអោយបានសំរេច ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

www.pheakdeylaw.com

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៤២ អនក្រ.បក**

**ស្តីពីការបង្កើតគណៈកម្មាធិការសំរុះសំរួល**

**ទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ**

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សំរេច

**មាត្រា ១ :** បង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍មួយមានឈ្មោះថា :

គណៈកម្មាធិការសំរុះសំរួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ ។

**មាត្រា ២ :** សមាសភាពគណៈកម្មាធិការនេះរួមមាន :

| | |
|---|---|
| ១-រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ប្រធាន |
| ២-សហអនុរដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣-តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៤-តំណាងក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន | សមាជិក |
| ៥-តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៦-តំណាងក្រសួងអប់រំយុវជន និង កីឡា | សមាជិក |
| ៧-មន្ត្រីនៃរដ្ឋលេខាធិការដ្ឋានមុខងារសារណៈ ០១ រូប | លេខាធិការ |

www.pheakdeylaw.com